ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០២៥

នៅក្នុងខែសីហា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម៖**
  - ❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖
    - ១- ពិនិត្យ និងសម្រេចលើសុពលភាពបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ១រូប តំណាងព្រឹទ្ធសភាទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។
    - ២- ពិនិត្យសំណើរបស់សមាជិកព្រឹទ្ធសភាស្នើសុំកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ។
    - ៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី សញ្ជាតិ។
    - ៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការអភិរក្ស និងជីវៈចម្រុះសមុទ្រប្រកបដោយចីរភាព នៅក្រៅដែនយុត្តាធិការជាតិក្រោមអនុសញ្ញាសហប្រជាជាតិស្តីពី ច្បាប់សមុទ្រ និង
    - ៥- កំណត់កាលបរិច្ឆេទ និងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។
  - ❖ បើកសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដើម្បីបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ១រូប តំណាងព្រឹទ្ធសភា។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

❖ កិច្ចប្រជុំពិភាក្សាការពារគម្រោងថវិកាឆ្នាំ២០២៦ របស់ព្រឹទ្ធសភា ជាមួយថ្នាក់ដឹកនាំតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

❖ កិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖

១- ការកំណត់ប្រធានបទសំខាន់ៗដើម្បីផ្សព្វផ្សាយទៅតាមមូលដ្ឋានដូចជា ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមាត្រា៣៣ ដើម្បីអនុញ្ញាតឱ្យមានការដកសញ្ជាតិខ្មែរ និង

២- ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

❖ សិក្ខាសាលាស្តីពី សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ដែលមានអ្នកចូលរួម១២០រូប រួមមានសមាជិកព្រឹទ្ធសភា តំណាងគណៈកម្មការទាំង១០នៃរដ្ឋសភា តំណាងគណបក្សនយោបាយ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងយុត្តិធម៌ តំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងតំណាងក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមជាមួយសមាជិក សមាជិកាព្រឹទ្ធសភា និងរដ្ឋសភា ក្រោមអធិបតីភាពរបស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ ចំនួន២ច្បាប់ នៅវិមាន៧មករា រួមមាន៖

  ១- សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី សញ្ជាតិ និង

  ២- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការអភិរក្ស និងជីវៈចម្រុះសមុទ្រប្រកបដោយចីរភាព នៅក្រៅដែនយុត្តាធិការជាតិ ក្រោមអនុសញ្ញាសហប្រជាជាតិស្តីពី ច្បាប់សមុទ្រ។

- អញ្ជើញចូលរួមក្នុងពិធីសច្ចាប្រណិធានចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ សម្រាប់អាណត្តិទី៤ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង និង
- អញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ លើកទី១ អាណត្តិទី៤ នៅអង្គភាពប្រឆាំងអំពើពុករលួយ។

## ២-មុខងារតាមដានការអនុវត្តច្បាប់

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា៖**

❖ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលជួបប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រុមប្រឹក្សាសកម្មភាពជនពិការ (ក.ស.ជ) ដឹកនាំដោយ **ឯកឧត្តម ម៉េត មករា** អនុប្រធាន ក.ស.ជ និង

ជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារទាក់ទងនឹងការលើកកម្ពស់សិទ្ធិជនពិការ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

❖ គណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញពិភាក្សាការងារជាមួយរដ្ឋបាលខេត្តព្រះសីហនុ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ក្រុមប្រឹក្សា និងគណៈអភិបាលស្រុកស្ទឹងហាវ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងកិច្ចការពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ។

❖ គណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីជួបសំណេះសំណាលជាមួយអាជ្ញាធរមានសមត្ថកិច្ច និងពិនិត្យស្ថានភាពនៃការវិលត្រឡប់របស់ពលករខ្មែរ នៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ច្រកទ្វារព្រំដែនអន្តរជាតិដូង ខេត្តបាត់ដំបង និងច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន។

❖ គណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចុះបេសកកម្ម ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ជាគ្រឿងឧបភោគ បរិភោគ និងថវិកា ចែកជូនជនភៀសសឹក ចំនួន៤០០គ្រួសារ ដែលកំពុងស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលសុវត្ថិភាព នៅវត្តព្រះពុទ្ធមានជ័យ ហៅវត្តប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ និង

❖ គណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ។

## ៣-មុខងារតំណាង

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**

- បានអញ្ជើញដង្ហែព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះអង្គយាងពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- បានអញ្ជើញតាមដានសភាពការណ៍វិវាទព្រំដែនកម្ពុជា-ថៃ និងផ្តល់ប្រឹក្សាយោបល់យុទ្ធសាស្ត្រយោធា ដល់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** និងបណ្តាមេទ័ព។
- បានអញ្ជើញពិនិត្យតាមដានសភាពការណ៍ ក្នុងការអនុវត្តដោយម៉ឺងម៉ាត់នូវបទឈប់បាញ់ ដើម្បីពង្រឹងកិច្ចការពារខ្លួនប្រឆាំងនឹងការរំលោភបំពានពីភាគីម្ខាងទៀត និង
- បានអញ្ជើញចូលរួមក្នុងពិធីបុណ្យទក្ខិណានុប្បទានគម្រប់១ឆ្នាំឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធ **សម្តេចចៅហ្វាវាំងវររៀងជ័យអធិបតីស្រីង្គារ គង់ សំអុល** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅវត្តជម្ពូវ័ន រាជធានីភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

▪ ***សកម្មភាពដឹកនាំកិច្ចប្រជុំ៖***

- បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយគណៈកម្មការទាំង១០ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារបន្តរបស់ក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយទីប្រឹក្សា អគ្គលេខាធិការរង និងមន្ត្រី ដើម្បីកំណត់ពេលវេលាចុះទៅសួរសុខទុក្ខ និងចែកអំណោយជូនវីរកងទ័ពនៅខេត្តសៀមរាប និងជូនបងប្អូនប្រជាពលរដ្ឋជនភៀសសឹក នៅក្នុងវត្តសុវណ្ណគិរី (ហៅវត្តឆែប) ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ និង
- បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទីប្រឹក្សា និងមន្ត្រី ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីផ្សព្វផ្សាយពីស្ថានការណ៍តាមព្រំដែនកម្ពុជា-ថៃ ដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ នៅស្រុកកងមាស ស្រុកព្រៃឈរ ស្រុកជើងព្រៃ និងក្រុងបាធាយ ខេត្តកំពង់ចាម។

▪ **បេសកកម្មក្នុងប្រទេស៖**

- បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** ចុះសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ឱសថ និងសម្ភារៈប្រើប្រាស់ផ្សេងៗ ជូនប្រជាពលរដ្ឋ និងកុមារភៀសសឹក មកពីតំបន់នានាតាមបណ្តោយព្រំដែន ចំនួន៧១០គ្រួសារ ដែលកំពុងស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលសុវត្ថិភាព វត្តភ្នំកំបោរ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។
- បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមពិធីសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ផ្សេងៗ ជូនប្រជាជនភៀសសឹកមកពីតំបន់នានាតាមបណ្តោយព្រំដែន ចំនួន៣៧៤គ្រួសារ ដែលកំពុងស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលសុវត្ថិភាពវត្តសុវណ្ណគិរី (ហៅវត្តឆែប) នៅស្រុកឆែប ខេត្តព្រះវិហារ។
- បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ចុះសួរសុខទុក្ខវីរកងទ័ព ចំនួន៤០នាក់ ដែលបាននិងកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសមៈ មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះកេតុមាលា រាជធានីភ្នំពេញ។
- បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីប្រគល់អំណោយជាគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់មួយចំនួន ជូនដល់កងពលតូចអន្តរាគមន៍លេខ៨ និងទីបញ្ជាការអន្តរាគមន៍ទួល៩៥ និងបានចុះសាកសួរសុខទុក្ខ

វីរយុទ្ធជនរងរបួស ចំនួន៣០នាក់ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែក ខេត្តសៀមរាប និង

- បានអញ្ជើញចុះជួបសំណេះសំណាល និងផ្សព្វផ្សាយអំពីសភាពការណ៍កម្ពុជា ជូនដល់មន្ត្រីរាជការ ប្រជាពលរដ្ឋ នៅស្រុកចំការលើ ស្រុកស្ទឹងត្រង់ ស្រុកកំពង់សៀម និងក្រុងកំពង់ចាម ខេត្តកំពង់ចាម។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**

- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធីប្រកាសលទ្ធផល និងប្រគល់ពានរង្វាន់ម្ចាស់ជ័យលាភីផ្ទើមពានរង្វាន់ "ត្នោតមាស" ឆ្នាំ២០២៥ ដោយមានការចូលរួមពីនិស្សិតប្រមាណជា៥០០នាក់ នៅទីស្នាក់ការមូលនិធិគីណាល់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។
- បានអញ្ជើញទទួលសម្តែងការគួរសម និងសំណេះសំណាល ថ្លែងអំណរគុណដល់ម្ចាស់អំណោយ ដែលបានជួយឧបត្ថម្ភជាស្បៀងអាហារ ព្រមទាំងសម្ភារៈប្រើប្រាស់មួយចំនួនសម្រាប់ចែកជូនប្រជាជនភៀសសឹក ក៏ដូចជាវីរកងទ័ពនៅតាមតំបន់ព្រំដែន។
- បានអញ្ជើញចូលរួមក្នុងពិធីបុណ្យឯករាជ្យជាតិលើកទី៧៩ នៃសាធារណរដ្ឋឥណ្ឌា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី៨០ឆ្នាំ ទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទឡ្ហនា អនុប្រធានទី២ព្រឹទ្ធសភា៖**

▪ **សកម្មភាពដឹកនាំ និងចូលរួមកិច្ចប្រជុំ៖**

- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យ ប្រចាំខែកក្កដា និងកំណត់ទិសដៅការងារខែសីហា ឆ្នាំ២០២៥ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យ ប្រចាំខែសីហា និងកំណត់ទិសដៅការងារខែកញ្ញា ឆ្នាំ២០២៥ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការទាំង១០ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារបន្តរបស់ក្រុមយន្តការនានារបស់ព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
- បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែ និងកំណត់ទិសដៅការងារបន្ត ជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **សកម្មភាពចុះមូលដ្ឋាន៖**
  - បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** អមដំណើរដោយ សមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ដឹកនាំខេត្ត ថ្នាក់ដឹកនាំខុទ្ទកាល័យអនុប្រធានទី២ ព្រឹទ្ធសភា មន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងតំណាងសភាពាណិជ្ជកម្ម អាមេរិក អឺរ៉ុប អូស្ត្រាលី អ៊ីស្រាអែល ឥណ្ឌា ហ្វីលីពីន សិង្ហបុរី និងក្រុមហ៊ុនឯកជន មួយចំនួនទៀត បានអញ្ជើញចុះពិនិត្យស្ថានភាពជាក់ស្តែងនៅព្រំដែនកម្ពុជា-ថៃ និង ជួបសំណេះសំណាលជាមួយប្រជាជនភៀសសឹក នៅខេត្តបន្ទាយមានជ័យ។
  - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា និងតំណាងសភាពាណិជ្ជកម្មអាមេរិក អឺរ៉ុប អូស្ត្រាលី ឥណ្ឌា ហ្វីលីពីន សិង្ហបុរី និងក្រុមហ៊ុនឯកជនមួយចំនួនទៀត ជួបជាមួយ **ឯកឧត្តម អ៊ុំ រាត្រី** អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និង**ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីឈ្វេងយល់អំពី ភូមិសាស្ត្រ និងស្ថានភាពភូមិជោគជ័យ និងភូមិព្រៃចាន់ នៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។
  - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា និងតំណាងសភាពាណិជ្ជកម្មអាមេរិក អឺរ៉ុប អូស្ត្រាលី ឥណ្ឌា ហ្វីលីពីន សិង្ហបុរី និងក្រុមហ៊ុនឯកជនមួយចំនួនទៀត ជួបជាមួយ **ឯកឧត្តម គីម រិទ្ធី** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ដើម្បីឈ្វេងយល់អំពី ស្ថានភាពរស់នៅរបស់ប្រជាជនភៀសសឹក នៅខេត្តព្រះវិហារ។
  - បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំភ្នំក្រាំងដីមាស ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដើម្បីឈ្វេងយល់អំពីលទ្ធផលការងារ បញ្ហាប្រឈម សំណូមពរ និងទិសដៅការងារបន្តរបស់រដ្ឋបាលឃុំ នៅសាលាឃុំភ្នំក្រាំងដីមាស។
  - បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃអង្គការសង្គ្រោះ វេជ្ជសាស្ត្រអន្តរជាតិប្រចាំនៅកម្ពុជា (IMR) និងសមាជិកក្រុមប្រឹក្សាសង្កាត់ទាំង៥ នៅ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
  - បានអញ្ជើញចុះទៅពិនិត្យស្រះចិញ្ចឹមត្រី និងការកែច្នៃត្រី ដើម្បីពិនិត្យលទ្ធភាពក្នុងការ ពង្រីកទីផ្សារផ្គត់ផ្គង់បន្ថែម នៅខេត្តកំពង់ឆ្នាំង។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាជាតិលើកទី៦០ នៃសាធារណរដ្ឋ សិង្ហបុរី នៅសណ្ឋាគាររាហ្វហ្វលល៍ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរបុណ្យឯករាជ្យជាតិលើកទី៧៩ នៃសាធារណរដ្ឋ ឥណ្ឌា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី៨០ឆ្នាំ ទិវាបុណ្យឯករាជ្យជាតិ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ។

- បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឧបាសិកា គីម សំ** ម្តាយបង្កើតរបស់ **ឯកឧត្តម សោម សារុជ** ជំនួយការខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ប្រធានព្រឹទ្ធសភា និង**លោក សោម វុឌ្ឍារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព និងឧបត្ថម្ភថវិកាដល់គ្រួសាររបស់ **លោកវរសេនីយ៍ត្រី លៀម សំពៅមាស** មន្ត្រីប៉ុស្តិ៍នគរបាលការពារព្រំដែនគោកអានសេះ នៃវរសេនាតូច នគរបាលការពារព្រំដែនគោកលេខ៧៩ និង**លោកអនុសេនីយ៍ឯក ពោ វៃ** បម្រើការងារនៅកងពលតូចលេខ៨ កងពលធំលេខ៣ ដោយបានពលីក្នុងសមរភូមិការពារដែនអធិបតេយ្យជាតិ និងបូរណភាពទឹកដី នៅសង្កាត់ព្រែកឯង និងសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ និងឧបត្ថម្ភថវិកាដល់គ្រួសារ **លោកវរសេនីយ៍ត្រី អ៊ួន ហាច** មេបញ្ជាការរងគ៣ វរសេនាតូចលេខ២ កងពលតូចអន្តរាគមន៍លេខ១ ដែលបានពលីជីវិតក្នុងសមរភូមិការពារដែនអធិបតេយ្យជាតិ និងបូរណភាពទឹកដី នៅខេត្តកំពង់ឆ្នាំង។
- បានអញ្ជើញចុះសួរសុខទុក្ខ ព្រមទាំងឧបត្ថម្ភថវិកា និងសម្ភារៈជូន **លោកអនុសេនីយ៍ឯក កុល វន** និង**លោកពលបាលឯក ស៊ីន សុវណ្ណ** ដែលបានរងរបួសក្នុងការបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តម ដើម្បីការពារដែនអធិបតេយ្យជាតិ និងបូរណភាពទឹកដី នៅមន្ទីរពេទ្យព្រះអង្គឌួង រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៧ថ្ងៃ **លោកឧត្តមសេនីយ៍ទោ សុខ វុធថន** នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និង**ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារបន្តរបស់ក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកម្មវិធីបើកនៃការចុះពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត (IMR) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅខណ្ឌកំបូល រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធី "ទិវាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី៩ ឆ្នាំ២០២៥" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តបាត់ដំបង និង

- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន១៤៨លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១៣១លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ និងជាប្រធានព្រឹទ្ធសភា អញ្ជើញ៖
  - ប្រចាំការ និងចូលរួមផ្តល់កិច្ចពិគ្រោះយោបល់ដល់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងស្ថានការណ៍រវាងកម្ពុជា-ថៃ និង
  - ចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់១ឆ្នាំ ឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធ **សម្តេចចៅហ្វាវាំងវររៀងជ័យអធិបតីស្រីធ្ការ គង់ សំអុល** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅវត្តជម្ពូវ័ន រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន៣លើក។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឧបាសិកា គឹម សំ** ម្តាយបង្កើតរបស់ **ឯកឧត្តម សោម សាវុធ** ជំនួយការខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា និង**លោក សោម វុឌ្ឍារិទ្ធ** អគ្គនាយករងនៃអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅគេហដ្ឋាននៃសព រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខម្តាយរបស់ **ឯកឧត្តម រ័ត្ន ហុក** នាយករងខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ចុះសួរសុខទុក្ខ និងនាំយកអំណោយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស៥ និងជាប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជូនដល់វីរកងទ័ពការពារប្រាសាទតាមាន់ ប្រាសាទតាក្របី និងមន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ នៅសាលាខេត្តឧត្តរមានជ័យ។

- ❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - ▪ អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញ៖
    - ចុះសួរសុខទុក្ខវីរកងទ័ពរងរបួសក្នុងការប្រយុទ្ធជាមួយពួកសៀមឈ្លានពាន ដែលកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសមៈ មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះកេតុមាលា រាជធានីភ្នំពេញ និង
    - ចុះសួរសុខទុក្ខ និងផ្តល់អំណោយឧបត្ថម្ភជូនដល់វីរយុទ្ធជនរងរបួស ដែលកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប និងជូនដល់កងកម្លាំងប្រដាប់អាវុធ និងប្រជាជនភៀសសឹក នៅខេត្តព្រះវិហារ។
  - ▪ អញ្ជើញចូលរួមប្រជុំពិភាក្សាអំពីការត្រៀមចុះសួរសុខទុក្ខវីរកងទ័ព និងប្រជាជនភៀសសឹក នៅខេត្តឧត្តរមានជ័យ ដឹកនាំដោយ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និង
  - ▪ អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៩លើក។
- ❖ **ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន១១លើក និង
- ❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣លើក។

- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គណៈកម្មការ ព្រមទាំងសមាជិក សមាជិកាដ៏ឧត្តុង្គឧត្តមទាំងអស់នៃព្រឹទ្ធសភា ដែលបានខិតខំបំពេញភារកិច្ចយ៉ាងសកម្ម និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ផ្សេងៗ ដើម្បីជាឧត្តមប្រយោជន៍ជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសសិរីមង្គលនៃថ្ងៃខួបចម្រើនជន្មាយុ គម្រប់៧៣ឆ្នាំ ឈានចូល៧៤ឆ្នាំ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរព្រះគុណ និងអរគុណរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងគោរពជូន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា និងឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងថ្នាក់ដឹកនាំ តាមក្រសួង

ស្ថាប័ននានា ដែលបានបញ្ជូនសារលិខិតជូនពរ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា ក្នុងឱកាសដ៏នក្ខត្តឫក្សនៃខួបចម្រើនជន្មាយុរបស់ **សម្តេចតេជោ**។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អគ្គស្នងការនៃសមាគមកាយឫទ្ធិនារីកម្ពុជា ក្នុងឱកាសដែលលោកជំទាវបណ្ឌិត ទទួលបាននូវពានរង្វាន់ "Smile Asia Philanthropic Visionary Award" លើកទី២ នៅក្នុងកម្មវិធី "Smile Asia Charity Gala 2025"។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គោរពជូន៖
    - **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស៥ និងជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
    - **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
    - **ឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត ប៉ុល សារឿន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
    - **ឯកឧត្តម យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា។
    - **ឯកឧត្តមបណ្ឌិត នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា។
    - **ឯកឧត្តម ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា។
    - **ឯកឧត្តមនាយឧត្តមសេនីយ៍ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង
    - **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន៖
    - **លោកជំទាវ ងិង វ៉ាន់នី** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តម នូ កឿង** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអតីតប្រធានក្រុមប្រឹក្សាខេត្តក្រចេះ និង
    - **ឯកឧត្តម សោម សាវុធ** ជំនួយការខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា និង**លោក សោម វុឌ្ឍារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឧបាសិកា គឹម សំ**។

- បានទទួលពាក្យបណ្តឹង ចំនួន៣បណ្តឹង បញ្ជូនពាក្យបណ្តឹងទៅមេធាវីស្ម័គ្រចិត្ត **សម្តេចតេជោសែន** ចំនួន១បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៣បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៥បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន១បណ្តឹង បានទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹង ចំនួន៥បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៥បណ្តឹង រំលឹកជំរុញការដោះស្រាយពាក្យបណ្តឹង ចំនួន២បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន៦បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន

២បណ្ដឹង បានទទួលលិខិតថ្លែងអំណរគុណពីម្ចាស់បណ្ដឹងគោរពជូនសម្ដេចតេជោប្រធានព្រឹទ្ធសភា តាមរយៈគណៈកម្មការ ចំនួន១បណ្ដឹង ។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**

❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ចំនួន៤លើក រួមមាន៖
  - **ឯកឧត្តម ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី (តាមប្រព័ន្ធទូរស័ព្ទ)។
  - **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម (តាមប្រព័ន្ធនិម្មិត)។
  - **ឯកឧត្តម U Khin Yi** ប្រធានគណបក្សសហភាពសាមគ្គី និងអភិវឌ្ឍន៍មីយ៉ាន់ម៉ា (USDP) នៅវិមាន៧មករា និង
  - **ឯកឧត្តម ម៉ាកូស ដូស រីអេស ដា កូស្តារ** (Marcos dos Reis da Costa) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅវិមានព្រឹទ្ធសភា។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញចូលរួម និងថ្លែងសុន្ទរកថាក្នុងពិធីអបអរសាទរខួបលើកទី៨០ នៃទិវាឯករាជ្យ របស់សាធារណរដ្ឋសង្គមនិយមវៀតណាម នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា** បានអនុញ្ញាតឱ្យគណៈប្រតិភូសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ចំនួន១២០នាក់ ដឹកនាំដោយ **លោក អ៊ុំ វុទ្ធី** ប្រធានក្រុមប្រឹក្សាភិបាលសមាគម ចូលជួបសម្ដែងការគួរសម និងទទួលអនុសាសន៍ មុននឹងចេញទៅបន្តការសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធស្នា អនុប្រធានទី២ព្រឹទ្ធសភា** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ចំនួន៣លើក រួមមាន៖

- **ឯកឧត្តម Shaharuddin Onn** ឯកអគ្គរដ្ឋទូតម៉ាឡេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សា និងសិក្សាអំពីលទ្ធភាពបង្កើនកិច្ចសហប្រតិបត្តិការការទូតសភា និងវិស័យផ្សេងៗទៀត រួមមាន អប់រំ សុខភាព ទេសចរណ៍ កសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម រវាងកម្ពុជាជាមួយម៉ាឡេស៊ី នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- **ឯកឧត្តម ស៊ូស៊ូមី ណាអូហ៊ីរ៉ូ** (TSUTSUMI Naohiro) ឯកអគ្គរាជទូតទទួលបន្ទុកសិទ្ធិមនុស្ស សន្តិភាព និងស្ថិរភាពអន្តរជាតិនៃក្រសួងការបរទេសជប៉ុន ដើម្បីពិភាក្សាការងារអំពីវឌ្ឍនភាព ស្ថានភាពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
- ប្រធានក្រុមហ៊ុន និងសមាគម Chuna Yu របស់ប្រទេសចិន ចូលជួបសម្ដែងការគួរសម និងប្រគល់អំណោយមនុស្សធម៌សម្រាប់ជូនដល់គ្រួសារយោធិនពលី កងទ័ពកំពុងបំពេញបេសកកម្មការពារព្រំដែនកម្ពុជា-ថៃ និងជនភៀសសឹក នៅសាលប្រជុំឧទ្ទកាល័យ។

❖ **ឯកឧត្តម ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា **ឯកឧត្តម ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា **ឯកឧត្តម ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា **ឯកឧត្តម ម៉ែន ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និង**ឯកឧត្តម ស៊ាក ឡេង** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយសក្នុងពិធីខួបលើកទី៦០ ទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋសិង្ហបុរី នៅសណ្ឋាគាររាហ្វហ្វលល៍ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបាន៖

- ទទួលជួបពិភាក្សាការងារជាមួយ **ឯកឧត្តម** Nikoloz Samkharadze សមាជិកសភា និងជាប្រធានគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិនៃសភាប្រទេសហ្សកហ្ស៊ី នៅការិយាល័យរបស់ឯកឧត្តមបណ្ឌិតប្រធានគណៈកម្មការ និង
- អញ្ជើញពិសាអាហារថ្ងៃត្រង់ការងារជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ និងលោកជំទាវឯកអគ្គរដ្ឋទូតសិង្ហបុរី នៅភោជនីយដ្ឋាន Ebinosekai Cambodia។

❖ **លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួម "សន្និសីទប្រធានសភាពិភពលោកលើកទី៦ និងកិច្ចប្រជុំកំពូលលើកទី១៥ នៃប្រធានសភាជាស្ត្រី" នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

❖ **លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងជាអនុប្រធានក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការ (AIPA) និង**ឯកឧត្តម អាយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងជាសមាជិកក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការ (AIPA) បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមការងារមួយចំនួន ដើម្បីទៅចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤៦ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ក្រោមអធិបតីភាពរបស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅអគាររដ្ឋបាលជាន់ទី១ បន្ទប់ហ្វូណន វិមានរដ្ឋសភា។

❖ សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពី "ការបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវពីថវិកាអាកាសធាតុ និងប្រសិទ្ធភាពនៃតួនាទីរបស់សភា ក្នុងការតាមដាន និងត្រួតពិនិត្យហិរញ្ញវត្ថុអាកាសធាតុនៅអាស៊ាន" (តាមប្រព័ន្ធនិម្មិត) នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង

❖ **ឯកឧត្តម ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី "កិច្ចសន្ទនាសភា៖ ការផ្សារភ្ជាប់ទំនាក់ទំនងសភារវាងសហភាពអឺរ៉ុប និងកម្ពុជា (Parliamentary Dialogue: EU-Cambodia Parliamentary Network)" នៅសាលសន្និសីទបន្ទាយស្រី វិមានរដ្ឋសភា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**
  - ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
    - ▪ អញ្ជើញចូលរួមអម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ចំនួន ៦លើក រួមមាន៖
      - ជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ នៅវិមានព្រឹទ្ធសភា វិមាន៧មករា និងតាមប្រព័ន្ធនិម្មិត ចំនួន៣លើក។
      - ពិធីអបអរសាទរខួបលើកទី៨០ នៃទិវាឯករាជ្យរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ និង
      - ពិធីជប់លៀងជូនគណៈប្រតិភូគណបក្សសហភាពសាមគ្គី និងអភិវឌ្ឍន៍មីយ៉ាន់ម៉ា។
    - ▪ អញ្ជើញជាកិត្តិយសក្នុងពិធីខួបលើកទី៦០ ទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋសិង្ហបុរី នៅសណ្ឋាគាររាហ្វហ្វលស៍ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ។
    - ▪ អញ្ជើញដឹកនាំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាមួយតំណាងក្រសួង/ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រៀមរៀបចំទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម** Ferdinand Romualdez Marcos Jr. ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និង**លោកជំទាវ** Louise Araneta-Marcos នៅព្រះរាជាណាចក្រកម្ពុជា។
    - ▪ ទទួលជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ង្វៀន មិញវូ** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា ដើម្បីពិភាក្សាការងារ និងផ្លាស់ប្ដូរយោបល់លើកិច្ចសហប្រតិបត្តិការនានា ដែលជាផលប្រយោជន៍រួមរវាងស្ថាប័នទាំងពីរ និងអំពីការរៀបចំទស្សនកិច្ចគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ដឹកនាំដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៨០ នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិវៀតណាម និង
    - ▪ អញ្ជើញចូលរួមពិសាអាហារការងារថ្ងៃត្រង់ជាមួយ **ឯកឧត្តម ង្វៀន មិញវូ** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា។
  - ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួងរដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានីភ្នំពេញ ស្ដីពី ការត្រៀមរៀបចំទស្សនកិច្ចផ្លូវរដ្ឋ របស់ **ឯកឧត្តម** Ferdinand Romualdez Marcos Jr. ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និង**លោកជំទាវ** Louise Araneta-Marcos នៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈិន កេតនា** ឧបនាយករដ្ឋមន្ត្រី អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទីនៃព្រះរាជាណាចក្រកម្ពុជា គោរពជូន៖
    - ▪ **ឯកឧត្តម លឿង គឿង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និង**ឯកឧត្តម ជិន ថាញ់មិន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឱកាសដ៏នក្ខត្តឫក្ស

នៃខួបលើកទី៨០ ទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

- **ឯកឧត្តម ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី និង**ឯកឧត្តម ស៊ុលតាន់ បាចទីយ៉ា ណាចាមូឌីន** ប្រធានក្រុមប្រឹក្សាតំណាងតំបន់នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ក្នុងឱកាសដ៏នក្ខត្តឫក្សនៃខួបលើកទី៨០ ទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋឥណ្ឌូណេស៊ី និង
- **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រី និង**ឯកឧត្តម ដាតុ អាវ៉ាង បៀមី ប៊ីន អាវ៉ាង អាលី បាសា** ប្រធានព្រឹទ្ធសភាម៉ាឡេស៊ី ក្នុងឱកាសដ៏នក្ខត្តឫក្សនៃខួបលើកទី៦៨ ទិវាបុណ្យឯករាជ្យជាតិម៉ាឡេស៊ី។

- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន (CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) បណ្ណសារដ្ឋានជាតិ និងក្រសួង/ស្ថាប័នដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** បានដឹកនាំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងដំណើរការវាយតម្លៃបន្តកិច្ចសន្យា ដើម្បីរៀបចំបែបបទវាយតម្លៃបុគ្គលិកជាប់កិច្ចសន្យា និងបន្តកិច្ចសន្យាការងារដល់បុគ្គលិកជាប់កិច្ចសន្យា នៅគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលពិសេសកណ្តាលវិមានព្រឹទ្ធសភា។
- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំប្រជុំការងាររៀបចំប្រាក់បៀវត្សខែកញ្ញា និងរៀបចំបោះផ្សាយអាណត្តិត្រីមាសទី៤ ឆ្នាំ២០២៥ ជាមួយនាយកដ្ឋានហិរញ្ញវត្ថុ នៅការិយាល័យឯកឧត្តមអគ្គលេខាធិការរង និង
- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងទិសដៅការងារបន្ត ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។

### ៥.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានបោះផ្សាយអាណត្តិជំពូក៦១ សម្រាប់ចំណាយលើបេសកកម្មក្នុងប្រទេស សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៥ ផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- បានស្នើសុំបុរេប្រទាន និងឥណទានបន្ថែម សម្រាប់ចំណាយលើបេសកកម្មរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៨០ នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិវៀតណាម។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែសីហា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែសីហា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៥។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៣៩សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១២៣សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារៈអនាម័យ សម្ភារៈការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៨សំណើ។
- បានថតចម្លងឯកសារ ចំនួន៣,៤៩៣ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន២៨,០៧៣សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ៦៥លើក ស្មើនឹង២១៨នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២១លើក។
- បានទទួលលិខិតចូល ចំនួន៧៨៤ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង/ស្ថាប័នពាក់ព័ន្ធនានា ចំនួន៣៧៤ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣១ច្បាប់ ស្មើនឹង២២០នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៦ច្បាប់។
- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ចំនួន៧នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
    - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន២២លើក។

- បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា និង
- បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។

- បានសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេស វិមានព្រឹទ្ធសភា។
- បានទាក់ទងជាមួយសាកលវិទ្យាល័យជាតិបាត់ដំបង ដើម្បីបណ្ដុះផ្កាកេសរកូលខ្មែរ ចំនួន៥០ពូជ ជូនអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា មានចំនួន៧១៤នាក់ (ស្រី២៨៩នាក់) ក្នុងនោះ
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់។
  - មន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៣នាក់ និង
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៧នាក់ (ស្រី៣៥នាក់)។
- បានពិនិត្យសេចក្ដីព្រាង និងសេចក្ដីសម្រេចស្ដីពី គោលការណ៍នៃការបើកផ្ដល់ និងទទួលថវិការបស់អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើសេចក្ដីសម្រេច ចំនួន៤ច្បាប់ និងលិខិតបង្គាប់ការ ចំនួន១ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្ទត់ផ្ទង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៥ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែសីហា ឆ្នាំ២០២៥។
- បានសម្របសម្រួល និងរៀបចំការផ្ដល់អាហារូបករណ៍ ចំនួន៣២កន្លែង របស់សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សាកលវិទ្យាល័យអាស៊ីអឺរ៉ុប សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យវ៉ាន់ដា និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ជូនដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានបញ្ជូនមន្ត្រីរាជការចំនួន ១៦នាក់ ចូលរួមសិក្ខាសាលា នៅសាធារណរដ្ឋប្រជាមានិតចិន ចំនួន ២វគ្គ ស្ដីពី៖
  - មន្ត្រីរាជការមកពីប្រទេសផ្ដួចផ្ដើមខ្សែក្រវាត់ និងផ្លូវ និង
  - ការចែករំលែកបទពិសោធន៍អភិបាលកិច្ចសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
  - បានជួសជុល និងលាបថ្នាំផ្ទាំងសម្រាប់ដាក់តាំងព្រះឆាយាល័ក្ខណ៍ នៅច្រកចេញ-ចូល P1 ចំនួន២ផ្ទាំង។
  - បានធ្វើស្លាកព្រឹទ្ធសភា ដាក់នៅអគារក្រហម។
  - បានជួសជុលថ្មក្រានីត នៅខាងមុខអគារក្រហម អគារស សាលពិសេស ព្រមទាំងបាន

សម្អាតម៉ាបតាមកាំជណ្ដើរ នៅអគារ DEF។

- បានជួសជុលពិដាន បិតការដំបូលស័ង្កសី បំពាក់កែងអូតូទ្វារដែក ប្តូរសន្លឹកទ្វារបន្ទប់ទឹក អ៊ុតកៅស៊ូការពារជម្រាបទឹក និងខាត់លាបជញ្ជាំង សសរម៉ាបខ្មៅ បង្កាន់ដៃដែក នៅនាយកដ្ឋានស្រាវជ្រាវថវិកា នាយកដ្ឋានព័ត៌មាន អគារស្នាក់នៅរបស់អង្គរក្ស និងសាលប្រជុំនានា និង
- បានសហការជាមួយក្រុមការងារស្ថាបត្យករ **លោក វណ្ណ មូលីវណ្ណ** ធ្វើការវាស់វែងអគារដែលជាស្ថាបត្យកម្មចាស់ មានដូចជា អគារក្រុមប្រឹក្សាធម្មនុញ្ញ អគារក្រុមប្រឹក្សានៃអង្គចៅក្រម និងអគារសហភាពសហព័ន្ធយុវជនកម្ពុជា។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្ដាញទឹក បណ្ដាញអគ្គិសនី ត្រួតពិនិត្យជណ្ដើរយន្ត កំចាត់សត្វកណ្ដៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារៈខូច បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងបំពាក់សម្ភារៈការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៩៤គ្រឿង/លើក។
- បានធ្វើស្លាកលេខរថយន្តព្រឹទ្ធសភាថ្មី ជូនសមាជិកព្រឹទ្ធសភា ចំនួន៣ឈុត។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្ដាហ៍ម្ដង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានស្រាវជ្រាវ និងរៀបចំចងក្រងសៀវភៅអំពីការវិវឌ្ឍនៃការប្រើប្រាស់អគារមួយចំនួន នៅវិមានព្រឹទ្ធសភា។
- បានស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងអគារនៃវិមានរដ្ឋចំការមន នៅបណ្ណាល័យនៃមជ្ឈមណ្ឌលខេមរភាសាសិក្សា (Center of Khmer Studies-CKF) និងវិទ្យាស្ថានបារាំងចុងបូព៌ាប្រទេស (EFEO) នៅខេត្តសៀមរាប។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្ដីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៥។

### ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ សេចក្ដីសម្រេច ប្រកាស និងលិខិតផ្សេងៗ ចំនួន៦ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្ដីព្រាងច្បាប់ពីទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួន២ច្បាប់ ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។

- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន២លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនលេខាធិការប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន ១លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រាយការណ៍ជូនអង្គប្រជុំ ចំនួន២លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនគណៈកម្មការបោះឆ្នោត ដើម្បីបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ចំនួន១លើក។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីចុះបេសកកម្មរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភា លើកទី៣ និងលើកទី៤ នីតិកាលទី៥ ចំនួន៣លើក។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន៤លើក។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៤៨លើក និង
- បានសម្របសម្រួលចុះបញ្ជី និងបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ទទួលការតែងតាំងថ្មីទៅអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន៣នាក់។

**៥.៤-ការងារស្រាវជ្រាវ៖**

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន២ច្បាប់ រួមមាន៖
  - វិសោធនកម្មច្បាប់ស្តីពី សញ្ជាតិ និង
  - ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះសមុទ្រប្រកបដោយចីរភាពនៅក្រៅដែនយុត្តាធិការជាតិ ក្រោមអនុសញ្ញាសហប្រជាជាតិស្តីពី សមុទ្រ។
- បានសិក្សាស្រាវជ្រាវ៖
  - អត្ថបទលើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
  - វិស័យគាំពារសង្គម។
  - ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និង
  - របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។
- បានសិក្សា និងតាមដាន៖
  - យុទ្ធសាស្ត្រស្តីពី ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០២៤-២០២៨។
  - របាយការណ៍ និន្នាការសេដ្ឋកិច្ច-សង្គម ប្រចាំខែរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
  - វឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។

- បានតាមដានការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និងការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
- បានសិក្សាស្រាវជ្រាវប្រមូលទិន្នន័យថវិកាមូលនិធិ ថ្នាក់ឃុំ សង្កាត់ ឆ្នាំ២០២៥។
- បានតាមដាន និងចងក្រងឯកសារយុទ្ធសាស្ត្រជាតិស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍នៃខែសីហា ឆ្នាំ២០២៥ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន២៣៧ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ៣៣-៣៧ ឆ្នាំ២០២៤)។

**៩.៩-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន២២លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,៥៥៣លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២៦៩សកម្មភាព។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៩លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខ្លោងទ្វារខាងមុខព្រឹទ្ធសភា ចំនួន១០លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន២៤ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារៈ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន៣០គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៤៣លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ ទស្សនាវដ្តី និងសៀវភៅជំនាញផ្សេងៗ ចំនួន១៥ក្បាល ព្រមទាំងបានបោះត្រាបិទបណ្ណខ្ចី និងសងសៀវភៅ ចំនួន៧ក្បាល។

- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៧២ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៧នាក់ (ដោយគិតត្រឹមខែសីហា ឆ្នាំ២០២៥) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ថែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ពួន) ឆ្នាំ២០១៤ ចំនួន៤៩០ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន២៩សំណុំ។

## ៩.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៣១លើក។
- បានរៀបចំសារលិខិតថ្លែងអំណរព្រះគុណ អរគុណ លិខិតជូនពរ និងលិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងជូនឥស្សរជនជាន់ខ្ពស់ និងថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា ចំនួន១៥លិខិត។
- បានរៀបចំកំណត់បង្ហាញ និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន ៦ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែសីហា ឆ្នាំ២០២៥ ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៨ច្បាប់ និង
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតជូនសមាជិកព្រឹទ្ធសភា ចំនួន១រូប និងលិខិតឆ្លងដែនផ្លូវការជូនទីប្រឹក្សាឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៤រូប។

## ៩.៧-ការងារអគ្គាធិការដ្ឋាន៖

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែសីហា ឆ្នាំ២០២៥។

- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែសីហា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤២លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែសីហា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារៈតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែកញ្ញា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើសន្ធិសញ្ញាស្តីពី តំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌ។
- ត្រៀមផ្តល់សេវាជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ ទី៧ និងទី៨ អញ្ជើញជួបសំណេះសំណាលជាមួយអង្គបោះឆ្នោត និងអ្នកពាក់ព័ន្ធ ព្រមទាំងចូលរួមដោះស្រាយ និងនាំយកយោបល់សំណូមពរជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តស្វាយរៀង និងខេត្តកំពង់ស្ពឺ និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។

- ត្រៀមសម្របសម្រួលរៀបចំបែបបទជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ច និងចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៨០ នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិវៀតណាម នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។
- ត្រៀមសម្របសម្រួលរៀបចំបែបបទដំណើរទស្សកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម** Ferdinand R. Marcos Jr ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅព្រះរាជាណាចក្រកម្ពុជា។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញចូលរួម៖
  - មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៦(46th AIPA) នៅទីក្រុងគូឡាឡាំពួនៃប្រទេសម៉ាឡេស៊ី។
  - សន្និសីទសភាអាស៊ី-ប៉ាស៊ីហ្វិកស្តីពី បរិស្ថាន និងការអភិវឌ្ឍលើកទី២១ (21st APPCED) នៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ។
  - កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាពនៃសភាតំបន់អាស៊ី(APA) នៅទីក្រុងម៉ាណាម៉ានៃប្រទេសបារ៉ែន និង
  - មហាសន្និបាតសហភាពអន្តរសភាលើកទី១៥១ និងកិច្ចប្រជុំពាក់ព័ន្ធ (151st IPU) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅខែតុលា ឆ្នាំ២០២៥។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នីតិកាលទី៥ ព្រឹទ្ធសភា។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថានអនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារៈ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ខែសីហា ជាខែទី២ នៃវិស្សមកាលរយៈពេលបីខែរបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការបង្កើនសកម្មភាពបំពេញមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង តាមរយៈការចុះមូលដ្ឋាន និងជំនួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ទិសដៅ និងបញ្ហាប្រឈម ការផ្សព្វផ្សាយច្បាប់ ការអនុវត្តច្បាប់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ព្រមទាំងបានផ្សារភ្ជាប់ជាមួយសកម្មភាពរួមចំណែកលើកទឹកចិត្តចំពោះកងទ័ពនៅសមរភូមិមុខ និងជួយប្រជាជនភៀសសឹក ដែលកំពុងជួបប្រទះនូវការលំបាក។

ក្រៅពីផ្តល់សេវានៅមូលដ្ឋាន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានផ្តល់សេវាលើមុខងារនីតិកម្ម ដោយបានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងរៀបចំដំណើរបំពេញបេសកកម្មក្រៅប្រទេស ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាជាមួយភ្ញៀវជាតិ និងអន្តរជាតិ បានដោយរលូន ទទួលបានលទ្ធផលផ្លែផ្កា ជាគុណប្រយោជន៍ជូនជាតិមាតុភូមិ។

ថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**